# ថ្នាំបង្ការជំងឺ COVID-19 - សំណួរដែលបានសួរជាញឹកញាប់

# ញាប់ ការមានផ្ទៃពោះ ការបំបៅដោះកូន និងការអាចមានកូន

## តើថ្នាំបង្ការជំងឺ COVID-19 ត្រូវបានណែនាំឱ្យផ្តល់ជូនសម្រាប់អ្នកមានផ្ទៃពោះដែរឬទេ?



ចាស/បាទ។ CDC និងអ្នកជំនាញទាក់ទងនឹងការមានផ្ទៃពោះ រួមមានមហាវិទ្យាល័យគ្រូពេទ្យឯកទេសផ្នែកសម្ភពនិងរោគស្ត្រីអាមេរិក សង្គមសម្រាប់វេជ្ជសាស្ត្រមាតាទារក និងមហាវិទ្យាល័យគិលានុបដ្ឋាយិការ-ឆ្មបរបស់អាមេរិក ណែនាំឱ្យអ្នកមានផ្ទៃពោះនិងអ្នកកំពុងផលិតទឹកដោះកូន ឱ្យទទួលការចាក់ថ្នាំបង្ការជំងឺ COVID-19។

មិនមានភស្តុតាងណាមួយដែលថាការចាក់ថ្នាំបង្ការជំងឺ COVID-19 បណ្តាលឱ្យមានបញ្ហាណាមួយទាក់ទងនឹងការមានផ្ទៃពោះទេ រួមទាំងការវិវឌ្ឍនៃដំណើររបស់សុកផងដែរ។ គិតត្រឹមខែកក្កដា ឆ្នាំ 2021 មានស្ត្រីដែលមានផ្ទៃពោះលើសពី 139,000 នាក់បានទទួលការចាក់ថ្នាំបង្ការ ហើយមិនមានបញ្ហាទាក់ទងនឹងការមានផ្ទៃពោះ ឬមានបញ្ហាទារកក្នុងផ្ទៃណាដែលមិនបានរំពឹងទុកមុន បានកើតឡើងនោះទេ។ មិនមានការរាយការណ៍ណាមួយអំពីការកើនឡើងនៃហានិភ័យ ការបាត់បង់គភ៌ បញ្ហាវិកលូតលាស់ ឬពិការភាពពីកំណើតនោះទេ។

ជំងឺ COVID-19 ផ្ទាល់តែម្តងគឺជាកង្វល់ដ៏ធ្ងន់ធ្ងរមួយក្នុងអំឡុងពេលមានផ្ទៃពោះ។ ស្ត្រីមានផ្ទៃពោះ និងមនុស្សដែលមានផ្ទៃពោះនាពេលថ្មីៗកន្លងមកនេះដែលមានជំងឺ COVID-19 ទំនងជាធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ហើយត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ជាងស្ត្រីដែលមិនមានផ្ទៃពោះ។ ពួកគេក៏ទំនងជារងផលវិបាកក្នុងពេលមានផ្ទៃពោះ ដូចជាការសម្រាលកូនមិនគ្រប់ខែ បើប្រៀបធៀបនឹងមនុស្សមានផ្ទៃពោះដែលមិនមានជំងឺ COVID-19។

ការចាក់ថ្នាំបង្ការជំងឺ COVID-19 អាចការពារស្ត្រីមានផ្ទៃពោះពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរពីជំងឺ COVID-19។ នៅក្នុងការសិក្សាអំពីមនុស្សដែលបានទទួលការចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ mRNA មានការរកឃើញអង់ទីក័រនៅក្នុងឈាមទងផ្ចិតរបស់ទារក និងក្នុងទឹកដោះម្តាយ។ នេះមានន័យថា ការចាក់ថ្នាំបង្ការក្នុងពេលមានផ្ទៃពោះក៏អាចជួយការពារទារកប្រឆាំងនឹងជំងឺ COVID-19 ផងដែរ។

ភស្តុតាងកាន់តែច្រើនឡើងៗ អំពីសុវត្ថិភាពនិងប្រសិទ្ធភាពនៃការចាក់ថ្នាំបង្ការជំងឺ COVID-19 អំឡុងពេលមានផ្ទៃពោះបង្ហាញថាអត្ថប្រយោជន៍នៃការទទួលការចាក់ថ្នាំបង្ការជំងឺ COVID-19 មានលើសពីហានិភ័យដែលបានដឹងឬអាចកើតមាន។ សម្រាប់ព័ត៌មានបន្ថែម សូមមើលការណែនាំរបស់សង្គមសម្រាប់វេជ្ជសាស្ត្រមាតាទារក អំពី ការចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រសិនបើអ្នកមានផ្ទៃពោះឬបំបៅដោះកូន និងគេហទំព័ររបស់ CDC អំពី ថ្នាំបង្ការជំងឺ COVID-19 នៅអំឡុងពេលមានផ្ទៃពោះឬបំបៅដោះកូន។

ប្រសិនបើអ្នកមានផ្ទៃពោះហើយមានសំណួរអំពីការចាក់ថ្នាំបង្ការ សូមពិគ្រោះជាមួយគ្រូពេទ្យ។ អ្នកក៏អាចពិគ្រោះជាមួយអ្នកជំនាញនៅមជ្ឈមណ្ឌល MotherToBaby ដែលអាចឆ្លើយសំណួរជាភាសាអង់គ្លេស ឬអេស្ប៉ាញ។ សេវាកម្មនេះគឺឥតគិតថ្លៃ និងរក្សាការសម្ងាត់ ដែលអាចបម្រើការជូនពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង5 ល្ងាច។ អ្នកអាចទូរស័ព្ទទៅលេខ 866-626-6847, ផ្ញើសារទៅលេខ 855.999.8525, អ៊ីមែល ContactUs@mothertobaby.org ឬចាប់ផ្តើមជជែកតាមរយៈគេហទំព័រ mothertobaby.org/ask-an-expert/។

## តើមនុស្សដែលកំពុងបំបៅដោះកូនដោយទឹកដោះអាចចាក់ថ្នាំបង្ការបានដែរឬទេ?



ចាស/បាទ។ អ្នកជំនាញរួមមាន CDC មហាវិទ្យាល័យពេទ្យឯកទេសផ្នែកសម្ភពនិងរោគស្ត្រីអាមេរិក សង្គមសម្រាប់វេជ្ជសាស្ត្រមាតាទារក និងមហាវិទ្យាល័យគិលានុបដ្ឋាយិការ-ឆ្មបរបស់អាមេរិក ណែនាំឱ្យអ្នកកំពុងបំបៅដោះកូន ឱ្យទទួលការចាក់ថ្នាំបង្ការជំងឺ COVID-19។

មនុស្សដែលកំពុងផលិតទឹកដោះកូនមិនត្រូវបានរាប់បញ្ចូលក្នុងការសិក្សាលើថ្នាំបង្ការនោះទេ។ ទោះយ៉ាងណាក៏ដោយផ្អែកលើអ្វីដែលពួកយើងដឹងអំពីរបៀបដែលថ្នាំបង្ការទាំងនេះដំណើរការ ថ្នាំបង្ការមិនត្រូវបានគេគិតថាជាហានិភ័យសម្រាប់ទារកទេ។ របាយការណ៍ថ្មីៗនេះបានបង្ហាញថា មនុស្សដែលបំបៅដោះកូនដែលបានចាក់ថ្នាំបង្ការ Pfizer ឬ Moderna មានអង់ទីក័រនៅក្នុងទឹកដោះម្ដាយរបស់ពួកគេ ដែលអាចជួយការពារកូនបាន។ ថ្នាំបង្ការទាំងនេះមិនឆ្លងចូលទឹកដោះម្ដាយទេ។

## តើខ្ញុំមានសុវត្ថិភាពក្នុងការចាក់ថ្នាំបង្ការជំងឺ COVID-19 ទេ ប្រសិនបើខ្ញុំចង់មានកូននៅថ្ងៃណាមួយ?

ចាស/បាទ។ CDC ណែនាំឱ្យការចាក់ថ្នាំបង្ការសម្រាប់មនុស្សទាំងអស់ដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ រួមទាំងមនុស្សដែលមានផ្ទៃពោះ កំពុងបំបៅដោះកូនដោយទឹកដោះ ព្យាយាមមានផ្ទៃពោះនាពេលឥឡូវនេះ ឬអាចនឹងមានផ្ទៃពោះនាពេលអនាគត។ អ្នកមានផ្ទៃពោះទំនងជាធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 បើប្រៀបធៀបនឹងអ្នកដែលមិនមានផ្ទៃពោះ។ លើសពីនេះទៀត អ្នកមានផ្ទៃពោះទំនងជាមានផលវិបាកដូចជាទារកកើតមិនគ្រប់ខែ ប្រសិនបើពួកគេឆ្លងជំងឺ COVID-19។

មិនមានភស្តុតាងណាមួយដែលបង្ហាញថាថ្នាំបង្ការជំងឺ COVID-19 បណ្តាលឱ្យមានបញ្ហាណាមួយទាក់ទងនឹងការមានផ្ទៃពោះទេ រួមទាំងការវិវត្តនៃដំណើររបស់សុកផងដែរ។ ដូចគ្នានេះផងដែរ មិនមានភ័ស្តុតាងណាមួយបង្ហាញពីបញ្ហាមានកូនរបស់ស្ត្រីឬបុរស គឺជាផលប៉ះពាល់នៃថ្នាំបង្ការណាមួយឡើយ រួមទាំងថ្នាំបង្ការជំងឺ COVID-19 ផងដែរ។ ថ្នាំបង្ការមិនផ្លាស់ប្តូរ DNA របស់មនុស្សណាមួយឡើយ ហើយក៏មិនមានភ័ស្តុតាងណាមួយដែលថ្នាំទាំងនេះជះឥទ្ធិពលដល់ភាពពេញវ័យ ឬការលូតលាស់របស់ក្មេងជំទង់ដែរ។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ ថ្នាំបង្ការជំងឺ COVID-19 សម្រាប់អ្នកដែលនឹងចង់មានកូន របស់ CDC។

## តើថ្នាំបង្ការជំងឺ COVID-19 អាចប៉ះពាល់ដល់ការមានរដូវរបស់ខ្ញុំដែរឬទេ?




ស្ត្រីខ្លះបានរាយការណ៍ពីការផ្លាស់ប្តូររដូវរបស់ពួកគេបន្ទាប់ពីចាក់ថ្នាំបង្ការ រួមទាំងការធ្លាក់ឈាមច្រើន និងរមួលឈឺចាប់ខ្លាំង។ យើងមិនទាន់ដឹងថាតើការផ្លាស់ប្តូរទាំងនេះគឺដោយសារតែថ្នាំបង្ការទេ - ការផ្លាស់ប្តូររដូវមិនទាន់ត្រូវបានគេរាយការណ៍ពីការសាកល្បងថ្នាំបង្ការទេ ហើយមិនទាន់មានលទ្ធផលនៃការសិក្សាលើបញ្ហានេះនៅឡើយ ដែរ។ វាជាការសំខាន់ដែលត្រូវចងចាំថា មានរឿងជាច្រើនដែលអាចបណ្តាលឱ្យមានការផ្លាស់ប្តូររដូវ ដូចជាភាពតានតឹង និងការផ្លាស់ប្តូរដំណេក របបអាហារ ការធ្វើលំហាត់ប្រាណ និងការប្រើថ្នាំមួយចំនួន។ រដូវមិនទៀងទាត់គឺជារឿងធម្មតាណាស់ក្នុងចំណោមក្មេងវ័យជំទង់ ហើយក៏ប្រហែលជាគ្មានមូលហេតុបង្កជាក់លាក់ទាល់តែសោះដែរ។ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីការមករដូវរបស់អ្នក ឬរបស់កូនអ្នក សូមពិភាក្សាជាមួយគ្រូពេទ្យ។